ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

លេខៈ...៣៤...ស.សរ

រាជធានីភ្នំពេញ, ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ ២០១៥

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតអនុគណៈកម្មការ និងក្រុមការងារ ជំនួយការឲ្យគណៈកម្មការអន្តរក្រសួង សម្រាប់រៀបចំទិវាវប្បធម៌ជាតិ ៣ មីនា លើកទី១៧ ឆ្នាំ២០១៥

## រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ០៦អនក្រ.ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៦ស្តីពីរៀបចំទិវាវប្បធម៌ជាតិ ៣ មីនា
- បានឃើញអនុក្រឹត្យលេខ២៤អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- តាមការចាំបាច់របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

## សម្រេច

**ប្រការ១ ៖**

- ត្រូវបានបង្កើតអនុគណៈកម្មការមួយដើម្បីជួយដល់គណៈកម្មការរៀបចំទិវាវប្បធម៌ជាតិ៣ មីនា លើកទី១៧ ឆ្នាំ២០១៥ ដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម ឃឹម សារិទ្ធ រដ្ឋលេខាធិការ ប្រធាន
២- ឯកឧត្តម ជុច ភឿន រដ្ឋលេខាធិការ អនុប្រធាន
៣- ឯកឧត្តម សំរ៉ង កំសាន្ត រដ្ឋលេខាធិការ អនុប្រធានអចិន្ត្រៃយ៍
៤- លោកជំទាវ ម៉ិញ ភុសនី រដ្ឋលេខាធិការ សមាជិកា
៥- ឯកឧត្តម អ៊ុក សុជាតិ រដ្ឋលេខាធិការ សមាជិក
៦- ឯកឧត្តម សោម សុគន្ធ រដ្ឋលេខាធិការ សមាជិក
៧- ឯកឧត្តម ថៃ នរៈសត្យា រដ្ឋលេខាធិការ សមាជិក
៨- ឯកឧត្តម អ៊ុន ឆឹម អនុរដ្ឋលេខាធិការ សមាជិក
៩- លោកជំទាវ ឆឹង ស៊ីមន អនុរដ្ឋលេខាធិការ សមាជិកា
១០- ឯកឧត្តម គង់ ភក្តារ៉ា អនុរដ្ឋលេខាធិការ សមាជិក
១០- ឯកឧត្តម ទិន ចណ្ឌីណាឌុច អនុរដ្ឋលេខាធិការ សមាជិក
១១- ឯកឧត្តម ហ៊ី ធីរៈ អនុរដ្ឋលេខាធិការ សមាជិក
១២- ឯកឧត្តម ស្រី សួន អនុរដ្ឋលេខាធិការ សមាជិក
១៣- លោកជំទាវ នេត្រ ភូម៉ារី អនុរដ្ឋលេខាធិការ សមាជិកា
១៤- ឯកឧត្តម ទៀង ចណ្ណនារុង អនុរដ្ឋលេខាធិការ សមាជិក

**អនុគណៈកម្មការនេះមានភារកិច្ចៈ**

ទទួលខុសត្រូវរួមលើដំណើការរៀបចំបើកមហោស្រពសិល្បៈយុវជន និងសកម្មភាពទិវាវប្បធម៌ជាតិ៣មីនា លើកទី១៧ ឆ្នាំ២០១៥។

**ប្រការ២ ៖**

ត្រូវបានបង្កើតក្រុមការងារលេខាធិការដ្ឋានមួយ ដើម្បីជួយដល់អនុគណៈកម្មការរៀបចំទិវាវប្បធម៌ជាតិ ៣មីនា លើកទី១៧ ឆ្នាំ២០១៥ ដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម អ៊ុន ឆឹម ប្រធាន
២- ឯកឧត្តម ឡុង ប៉ុណ្ណាសិរីវឌ្ឍ អនុប្រធាន អចិន្ត្រៃយ៍
៣- លោក ព្រំ សំអឿន អនុប្រធាន
៤- លោក ឡាយ សំអូន សមាជិក
៥- លោក ទិន វិឡេដ្ឋ សមាជិក
៦- លោក យ៉ុន អាន សមាជិក
៧- លោក សែន កុសល សមាជិក
៨-លោក ម៉ែន សេរីវុឌ្ឍ សមាជិក
៩-លោក ច័ន្ទ វណ្ណា សមាជិក
១១-លោក កែវ កាន់ធីរៈ សមាជិក
១២-លោក មួង ច័ន្ទទាសនា សមាជិក
១៣- លោក ម៉ាន ធីរៈ សមាជិក

១៤- លោក **ហ៊ីម និមល** សមាជិក

១៥- លោក **លឹម យុស្ទ** សមាជិក

**ក្រុមការងារលេខាធិការដ្ឋាននេះមានភារកិច្ច ៖**

- រៀបចំសកម្មភាពប្រឡងប្រជែងដណ្តើមពានរង្វាន់ទិវាវប្បធម៌ជាតិ ៣ មីនា លើកទី១៧ ឆ្នាំ២០១៥ របស់និស្សិត នៅតាមស្ថានីយទូរទស្សន៍
- រៀបចំផ្សព្វផ្សាយ និងទទួលខុសត្រូវលើការប្រឡងប្រជែងគូគំនូរផ្សាយ «អាហ្វីស» ទិវាវប្បធម៌ជាតិ៣ មីនាលើកទី១៧ ឆ្នាំ២០១៥
- តាក់តែងផែនការ សារាចរណែនាំ ផលិតឯកសារ លិខិតបទដ្ឋានដែលពាក់ព័ន្ធនឹងការបើកមហោស្រព យុវជន និងទិវាវប្បធម៌ជាតិ ៣ មីនាលើកទី១៧ ឆ្នាំ២០១៥
- រៀបចំកិច្ចប្រជុំគណៈកម្មការអន្តរក្រសួង និងអនុគណៈកម្មការ
- លើកគម្រោងស្នើសុំថវិការដ្ឋ
- គ្រប់គ្រង បែងចែក ផ្គត់ផ្គង់សម្ភារៈ និងថវិកាសម្រាប់សកម្មភាពបើកមហោស្រពយុវជន និងទិវាវប្បធម៌ជាតិ ៣ មីនា
- រៀបចំកម្មវិធី បោះពុម្ពលិខិតអញ្ជើញ ស្លាករថយន្ត ប័ណ្ណសមាជិក ប័ណ្ណសន្តិសុខ
- ផលិត និងបោះពុម្ពអាហ្វីស បម្រើឲ្យសកម្មភាពបើកមហោស្រពយុវជន និងទិវាវប្បធម៌ជាតិ ៣ មីនា
- រៀបចំសន្តិសុខ សុវត្ថិភាពជូនអង្គពិធីទាំងមូល
- តាក់តែងសុន្ទរកថាជូនថ្នាក់ដឹកនាំក្នុងឱកាសបើក និងបិទមហោស្រពសិល្បៈយុវជននិងទិវាវប្បធម៌ជាតិ ៣ មីនាលើកទី១៧ ឆ្នាំ២០១៥
- បំពេញភារកិច្ចផ្សេងទៀតដែលអនុគណៈកម្មការរៀបចំទិវាវប្បធម៌ជាតិ ៣ មីនា លើកទី១៧ ឆ្នាំ២០១៥ ប្រគល់ជូន។

**ប្រការ៣ ៖**

- ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសមួយដើម្បីជួយដល់អនុគណៈកម្មការរៀបចំទិវាវប្បធម៌ជាតិ ៣មីនាលើកទី១៧ ឆ្នាំ២០១៥ ដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម **សំរ៉ែង កំសាន្ត** ប្រធាន

២- ឯកឧត្តម **ហាច់ ឆួច** អនុប្រធាន អចិន្ត្រៃយ៍

៣- លោក **យស់ ខៀន** អនុប្រធាន

៤- លោក **ដួង សាមុត** សមាជិក

៥- លោក **ឯក ម៉ុនថា** សមាជិក

៦- លោកស្រី **ហ៊ើល ភឿនណារី** សមាជិកា

៧-លោក **ម៉ៅ អេង** សមាជិក

៨-លោកស្រី **រស់ សារុ** សមាជិកា

៩-លោក **ស៊ិន ច័ន្ទសាយ៉ា** សមាជិក

១០-លោក **ហ៊ឹម ទិមុលធល** សមាជិក

១១- លោក **សាន សំអាង** សមាជិក

**ក្រុមការងារបច្ចេកទេសនេះមានភារកិច្ចៈ**

- ទទួលខុសត្រូវលើដំណើការបើកមហោស្រពសិល្បៈយុវជន
- ទទួលខុសត្រូវលើដំណើរការរៀបចំសិក្ខាសាលាថ្នាក់ជាតិ ដើម្បីត្រៀមរៀបចំបើកមហោស្រពសិល្បៈយុវជន
- ផ្សព្វផ្សាយ និងចាត់តាំអនុវត្តសេចក្តីសម្រេចចិត្តរបស់អង្គសិក្ខាសាលាជាតិ
- ទំនាក់ទំនង និងសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- រៀបចំខ្លឹមសារប្រធានបទ កម្មវិធីសម្តែង និងគាក់តែងផែនការណែនាំពាក់ព័ន្ធនឹងការបើកមហោស្រព និងការសម្តែងសិល្បៈយុវជនក្នុងឱកាសទិវាវប្បធម៌ជាតិ ៣ មីនាលើកទី១៧ ឆ្នាំ២០១៥
- ផលិត និងបោះពុម្ពសៀវភៅផ្តត់បម្រើឲ្យសកម្មភាពទិវាវប្បធម៌ជាតិ ៣ មីនា លើកទី១៧ ឆ្នាំ២០១៥
- ផលិតឯកសាររូបភាព និងផ្សព្វផ្សាយព័ត៌ផ្សេងៗមានពាក់ព័ន្ធនឹងទិវាវប្បធម៌ជាតិ ៣ មីនាលើកទី១៧ ឆ្នាំ២០១៥
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការបើកមហោស្រពសិល្បៈយុវជន និងសកម្មភាពការងាររៀបចំទិវាវប្បធម៌ជាតិ ៣ មីនាលើកទី១៧ ឆ្នាំ២០១៥
- បំពេញការកិច្ចផ្សេងទៀតដែលអនុគណៈកម្មការរៀបចំទិវាវប្បធម៌ជាតិ៣ មីនា លើកទី១៧ ឆ្នាំ២០១៥ ប្រគល់ជូន ។

**ប្រការ៤ ៈ**

- ត្រូវបានបង្កើតក្រុមការងារបដិសណ្ឋារកិច្ចមួយ ដើម្បីជួយដល់ក្រុមលេខាធិការដ្ឋានរៀបចំទិវាវប្បធម៌ជាតិ ៣ មីនា លើកទី១៧ ឆ្នាំ២០១៥ ដែលមានសមាសភាពដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| ១- លោក | **កែវ** | **ភាន់ទិវៈ** | ប្រធាន |
| ២- លោក | **អ៊ុំន** | **សុខា** | អនុប្រធាន |
| ៣- លោកស្រី | **ហ៊ីន** | **ម៉ែន** | អនុប្រធាន |
| ៤- កញ្ញា | **ជា** | **ណារិន** | សមាជិកា |
| ៥- លោកស្រី | **ឡុង** | **សុណា** | សមាជិកា |
| ៦- លោកស្រី | **គួច** | **គន្ធិកា** | សមាជិកា |
| ៧- លោកស្រី | **សុខ** | **ស៊ីដូនី** | សមាជិកា |
| ៨- លោក | **ម៉ុនថន** | **សុថាណារិទ្ធ** | សមាជិក |
| ៩- លោក | **គន** | **សុវណ្ណឧត្តម** | សមាជិក |
| ១០- លោក | **គង់** | **សុធារិទ្ធ** | សមាជិក |
| ១១- លោក | **សោម** | **វណ្ណៈ** | សមាជិក |

**ក្រុមការងារនេះមានភារកិច្ចៈ**

- រៀបចំបដិសណ្ឋារកិច្ចតាមកម្មវិធីដែលបានកំណត់
- ចាត់តាំងកម្មវិធី
- ការកិច្ចផ្សេងទៀតដែលប្រធានក្រុមលេខាធិការដ្ឋានប្រគល់ជូន

**ប្រការ៥ ៖**

- រាល់ការចំណាយរបស់ក្រុមការងារនីមួយៗត្រូវធ្វើគម្រោង លម្អិតដើម្បីស្នើសុំការសម្រេចពីប្រធានអនុគណៈកម្មការរៀបចំទិវាវប្បធម៌ជាតិ ៣ មីនា លើកទី១៧ ឆ្នាំ២០១៥

**ប្រការ៦ ៖**

- ក្រុមការងារដូចមានចែងក្នុងប្រការ១ ,ប្រការ២,ប្រការ៣ និងប្រការ៤ ខាងលើ មានសិទ្ធប្រើប្រាស់មន្ត្រីក្រោមឱវាទឲ្យជួយការងារបាន តាមការចាំបាច់ៗ

**ប្រការ៧ ៖**

នាយកខុទ្ទកាល័យ អធិការនៃអធិការដ្ឋាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ អគ្គនាយកបេតិកភណ្ឌ សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ នាយកសាលាមធ្យមវិចិត្រសិល្បៈ គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១-២-៣ និងប្រការ៤ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*ចម្លងជូន៖*

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គណៈកម្មាធិការបុណ្យជាតិ- អន្តរជាតិ
- គណៈកម្មការអន្តរក្រសួងរៀបចំទិវាវប្បធម៌ជាត៣មីនា
- សាលារាជធានីភ្នំពេញ
- ឯកសារ-កាលប្បវត្តិ

**រដ្ឋមន្ត្រី**

ភឿង - សកុណា